World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្ដីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៥

របាយការណ៍គិតត្រឹមថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី៤ មេសា ដល់ថ្ងៃ ១៧ មេសា ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ២៩៤ និងករណីស្លាប់ថ្មីដោយសារជំងឺកូវីដ-១៩ចំនួន ១ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោមករណីនោះ  ២៩២ករណី ឬ ៩៩ភាគរយជាករណីឆ្លងក្នុងសហគមន៍ ហើយ ២ករណី ឬ ១ភាគរយជាករណីនាំ ចូលពីក្រៅប្រទេស។ ចំនួនករណីឆ្លងថ្មីបានធ្លាក់ចុះចំនួន ៥៨ភាគរយ និងករណីស្លាប់បានធ្លាក់ចុះចំនួន ៥០ ភាគរយ បើធៀបទៅនឹងរយៈពេល១៤ថ្ងៃកន្លងទៅ។

- គិតត្រឹមថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២២ ករណីសរុបទាំងអស់ចំនួន ១៣៦.០៧៦  ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥៥ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ  ១៣២.៧៨៩ករណីបានជាសះស្បើយ។

- គិតត្រឹមថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៦១០.៩៨៥ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)។ គិតចាប់តាំងពីខែមករា ឆ្នាំ ២០២០មក បុគ្គលសរុបចំនួន ១.៨៦៥.៣២១  នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥.២ ភាគរយ។

- ចំនួនករណីឆ្លងវីរុសកូវីដ-១៩ថ្មីដែលត្រូវបានរាយការណ៍ បន្តធ្លាក់ចុះជាបន្តបន្ទាប់នៅក្នុងរយៈពេលពីរសប្តាហ៍កន្លងមកនេះ។ តែទោះបីជាយ៉ាងណា ការចម្លងកើនឡើងដោយសារចលនាធ្វើដំណើរក្នុងស្រុកច្រើន និងការជួបជុំទ្រង់ទ្រាយធំកំឡុងពេលចូលឆ្នាំថ្មីប្រពៃណីខ្មែរ។ សមត្ថភាពថែទាំសុខភាពនៅតែមានស្ថេរភាពជាមួយនឹងករណីជំងឺកូវីដ-១៩ភាគច្រើនកំពុងទទួលការថែទាំ និងសះស្បើយនៅតាមផ្ទះ។

- ការកំរិតវិធានការសុខាភិបាល និងសង្គមដើម្បីទប់ស្កាត់កុំឱ្យមានការចម្លងទ្រង់ទ្រាយធំ ការពង្រឹងការផ្តល់សេវាសុខភាព និងពន្លឿនការចាក់វ៉ាក់សាំងសម្រាប់ក្រុមប្រជាជនដែលងាយរងគ្រោះ នៅតែជាផ្នែកអាទិភាពដើម្បីគ្រប់គ្រងកូវីដ-១៩ និងបញ្ហាផ្សេងៗនាពេលអនាគតប្រកបដោយនិរន្តរភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដាន:**

❖ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ក្រោមការផ្តល់បច្ចេកទេសពីអង្គការសុខភាពពិភពលោកកំពុងរៀបចំការតាមដានការចូលរួមរបស់សហគមន៍ដើម្បីពង្រឹងការរកឃើញជំងឺកូវីដ១៩ឲ្យបានឆាប់ និងជំងឺឆ្លងអេពីដេមីសាស្ត្រដ៏ទៃទៀត។

❖ អង្គការសុខភាពពិភពលោកកំពុងពង្រឹងសម្ថភាពដល់មន្ត្រីសុខាភិបាលថ្នាក់ខេត្តតាមរយៈអនុវត្តលំហាត់សមយុទ្ធអំពីការអង្កេតជាចង្កោមទៅលើទីតាំងហានិភ័យខ្ពស់ និងក្រុមងាយរងគ្រោះ

## វិធានការសុខាភិបាល និងសង្គម

❖ នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២២ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយកមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចលើកលែងកាតព្វកិច្ចពាក់ម៉ាស់ក្នុងខេត្តចំនួន៤(ខេត្តរតនគីរី  មណ្ឌលគីរី  ស្ទឹងត្រែង  និងព្រះវិហារ)។  ក្រសួងសខាភិបាលបានចេញព្រឹតិបត្តិព័ត៌មានចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ថ្លែងថា ប្រជាជនទាំអស់ក្នុងខេត្តទាំង៤អាចជ្រើសរើសដោយខ្លួនឯងពីការបន្តពាក់ម៉ាសរឺមិនពាក់ម៉ាស់  ប៉ុន្តែកាតព្វកិច្ចពាក់ម៉ាស់នេះត្រូវបន្តអនុវត្តនៅខេត្តដ៏ទៃទៀត។ អាជ្ញាធរមូលដ្ឋានត្រូវយកទុកដាក់លើការងារនេះដើម្បីធានាសមត្ថ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ភាពប្រព័ន្ធសុខាភិបាល ធ្វើការស្វែងរកអោយបានរហ័ស និងឆ្លើយតបទាន់ពេលវេលា។ តាមរយៈរបាយការណ៍រាយការប្រចាំថ្ងៃអំពីជំងឺកូវីដ១៩ពីមន្ទីរសុខាភិបាលខេត្តតាមដានទំនោរនៃការចម្លង និងអ្នកដែលមានរោគសញ្ញាកូវីដ១៩ត្រូវធ្វើតេស្តខ្លួនឯង។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- អង្គការសុខភាពពិភពលោកបានធ្វើវិចារណកថាមុនពិធីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដើម្បីរំឭកប្រជាពលរដ្ឋឲ្យរក្សាការប្រុងប្រយត្ន័ខ្ពស់នៅក្នុងពេលប្រព្វពិធីចូលឆ្នាំជាមួយមនុស្សជាទីស្រឡាញ់របស់ពួកគេ។
- អង្គការសុខភាពពិភពលោក កំពុងធ្វើការងារជាមួយនឹងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខភិបាល និងដៃគូផ្សេងទៀត រៀបចំប្រារព្ធទិវាលាងសំអាតដៃពិភពលោក ឆ្នាំ ២០២២ និងផលិតសំភារៈអប់រំមួយចំនួន។
- មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពដោយមានការគាំទ្របច្ចេកទេសពីអង្គការសុខភាពពិភពលោកនឹងផ្តួចផ្តើម " ការអនុវត្តការចូលរួមរបស់សហគមន៍ និងការតាមដានដោយមានការចូលរួមរបស់ហាគមន៍ចំពោះជំងឺកូវិត-១៩ ជំងឺផ្តាសាយ និង មេរោគផ្លូវដង្ហើមផ្សេងៗ " រួមទាំងអនុវត្តសកម្មភាពបង្កើនសមត្ថភាពដល់បុគ្គលិកមន្ទីរសុខាភិបាលខេត្ត ស្រុកប្រត្តិបត្តិ និងបុគ្គលិកបណ្ឌលសុខភាពនៅក្នុងខេត្តអាទិភាពចំនួន ៩ នៅក្នុងប្រទេសកម្ពុជា បាប់ពីខែ មេសា ឆ្នាំ ២០២២ នេះ។
- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់ បានបង្កើតយុទ្ធនាការផ្សព្វផ្សាយតាមបណ្តាញសង្គម នៅក្នុងពិធីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដើម្បីឲ្យប្រជាពលរដ្ឋមានការយកចិត្តទុកដាក់ប្រុងប្រយត្ន័ខ្ពស់ បន្តអនុវត្តវិធានការការពារ និងជួយជំរុញសមាជិកគ្រួសាររបស់គេ មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន និងមិត្តភ័កទៅចាក់វ៉ាក់សាំងដូសជំរុញតាមការណែនាំរបស់ក្រសួងសុខាភិបាល។







ការផ្សព្វផ្សាយនៅលើទំព័របណ្តាញសង្គមរបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល នៅក្នុងពិធីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ស្តីអំពីវិធានការការពារជំងឺកូវិត-១៩ និងការចាក់វ៉ាក់សាំង។

- អង្គការសុខភាពពិភពលោកបានធ្វើបច្ចុប្បន្នភាពបញ្ជីសំណួរចម្លើយអំពីការថែទាំសមាជិកគ្រួសារ និង អ្នកថែទាំតាមផ្ទះ ដោយមានសំណួរថ្មីៗអំពីការថែទាំកុមារនៅតាមផ្ទះ:https://www.who.int/emergencies/diseases/novel-coronavirus-2019/question-and-answers-hub/q-a-detail/coronavirus-disease-covid-19-home-care-for-families-and-caregivers



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- វ៉ាក់សាំងកូវីដ-១៩ ប្រភេទ COVISHIELD ចំនួន ៣២៥,000 ដូស ដែលបរិច្ចាគពីប្រទេសឥណ្ឌា បានមកដល់ប្រទេសកម្ពុជាហើយការពីសប្តាហ៍មុន។ មកដល់ថ្ងៃនេះប្រទេសកម្ពុជាបានទទួលវ៉ាក់សាំងកូវីដ-១៩ ទាំងអស់ចំនួន ៥៩,៧៧៩,៨៦០ ដូស ។
- អង្គការ GAVI បានជូនដំណឹងជាផ្លូវការមកកម្ពុជាថា COVAX បានសម្រេចចិត្តបង្កើនការផ្តល់វ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារទៅកាន់ប្រទេសដែលមានអត្រាគ្របដណ្តប់វ៉ាក់សាំងកូវីដ-១៩ ខ្ពស់ ហើយប្រទេសកម្ពុជាត្រូវបានផ្តល់អាទិភាពក្នុងការទទួលវ៉ាក់សាំងប្រភេទ Pfizer ប្រើប្រាស់សំរាប់កុមារផងដែរ។
- យុទ្ធនាការផ្តល់វ៉ាក់សាំងកូវីដ-១៩ ធ្វើឡើងក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ និងក្រោយបុណ្យចូលឆ្នាំខ្មែរដល់ប្រជាពលរដ្ឋដែលមិនទាន់បានទទួលវ៉ាក់សាំងដូសមូលដ្ឋានគ្រប់ និងដូសជំរុញតាមរយៈ៖
    - ❖ ការបង្កើនទីតាំងផ្តល់វ៉ាក់សាំងកូវីដ-១៩ ចល័ត នៅតាមវត្តអារាម រោងចក្រ សាលារៀន ទីសាធារណៈ និងកន្លែងកំសាន្ត ឬ តំបន់ទេសចរណ៍នានានៅទូទាំងប្រទេសកម្ពុជា។
    - ❖ បន្តអនុវត្តការផ្តល់វ៉ាក់សាំងកូវីដ-១៩ នៅតាមទីប្រជុំជន តំបន់ក្រីក្រ ជនជាតិភាគតិច និងសហគមន៍ដែលមានហានិភ័យខ្ពស់។
    - ❖ ធ្វើការសម្របសម្រួលរវាងវិស័យសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន វិស័យសាធារណៈ និងឯកជន ដើម្បីទទួលបានការណែនាំច្បាស់លាស់មួយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់ដែលពួកគាត់ទទួលវ៉ាក់សាំងដូសមូលដ្ឋានគ្រប់ចំនួន(២ដូស) និងដូសជំរុញ។
    - ❖ កៀរគរអ្នកគាំទ្រពីមូលដ្ឋានដើម្បីកំណត់អត្តសញ្ញាណ និងចុះឈ្មោះអ្នកដែលខកខាន និងមិនទាន់បានទទួល ដូសមូលដ្ឋានគ្រប់ចំនួន(២ដូស) និងដូសជំរុញដើម្បីបង្កើនការយល់ដឹង/តម្រូវការ ធ្វើការផ្សព្វផ្សាយ និងតាមដានពួកគាត់មកទទួលវ៉ាក់សាំង។
    - ❖ កៀរគរក្រុមចាក់វ៉ាក់សាំងក្រៅពីក្រសួងសុខាភិបាល (ឧ. ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រុមគ្រូពេទ្យស្ម័គ្រ ចិត្តសម្តេចវិបុលសេនាភក្តីសាយ ឈុំ និង សម្ព័ន្ធគ្រូពេទ្យសហភាពសហពន្ធ័យុវជនកម្ពុជា។
- អង្គការសុខភាពពិភពលោកគាំទ្រទាំងបច្ចេកទេស និង ថវិការដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ (NIP)៖
    - ❖ កំណត់អត្តសញ្ញាណអ្នកដែលខកខាន និងមិនទាន់បានទទួលវ៉ាក់សាំងដូសមូលដ្ឋានគ្រប់ចំនួន(២ដូស) និងដូសជំរុញ កសាងផែនការលំអិត នៅថ្នាក់ក្រោមជាតិ ការអនុវត្តនៅកន្លែងដែលបានកំណត់ និងក្រុមចល័តទៅកាន់សហគមន៍ដាច់ស្រយាល/ពិបាកទៅដល់ សហគមន៍ដែលមានហានិភ័យខ្ពស់ និង ការចូលរួមសហគមន៍ ការពិនិត្យ និងការតាមដានដើម្បីអោយបានទៅដល់ប្រជាជនដែលមានសិទ្ធិទាំងអស់ក្នុងប្រទេសកម្ពុជា។
    - ❖ ឧបត្ថម្ភថវិកាដល់ខេត្តបាត់ដំបង សៀមរាប កំពង់ឆ្នាំង និងកំពង់ស្ពឺ ដើម្បីចុះផ្តល់វ៉ាក់សាំងនៅតាមភូមិ ឬសហគមន៍ នៅតាមបឹងទន្លេសាប និងភូមិដាច់ស្រយាលផ្សេងៗទៀត។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- អង្គការសុខភាពពិភពលោកកំពុងគាំទ្រដល់ក្រសួងសុខាភិបាល ដើម្បីធ្វើបច្ចុប្បន្នភាពនៃពិធីសារក្នុងការគ្រប់គ្រងព្យាបាលជំងឺកូវីដ-១៩ (កំណែលើកទី៦) ដោយដាក់បញ្ចូលនូវសារសំខាន់ៗបន្ថែមទៀត សម្រាប់ការប្រើប្រាស់ឪសថម៉ូលនូពីរ៉ាវ ផ្អែកទៅលើអនុសាសន៍របស់អង្គការសុខភាពពិភពលោក ដែលមានរាប់បញ្ចូលនូវការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ និងការព្រួយបារម្ភទាក់ទងនឹងសុវត្ថិភាព សម្រាប់គ្រូពេទ្យព្យាបាល និងអ្នកប្រើប្រាស់ទូទៅ ដែលត្រូវប្រើឪសថនេះ។
- អង្គការសុខភាពពិភពលោកកំពុងគាំទ្រដល់នាយកដ្ឋានមន្ទីរពេទ្យ ដើម្បីពង្រាងគោលការណ៍ណែនាំសម្រាប់អនុវត្តការធ្វើសមាហរណ៍កម្មសេវាព្យាបាលជំងឺកូវីដ-១៩ទៅក្នុងប្រព័ន្ធថែទាំផ្នែកសុខាភិបាលតែ មួយ។ គោលការណ៍ណែនាំសម្រាប់អនុវត្តនេះ ត្រូវគេរំពឹងថានឹងដាក់ចេញឲ្យអនុវត្តជាផ្លូវការដោយក្រសួងសុខាភិបាលក្នុងពេលឆាប់ៗនេះ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ ២០២១-២០២២*




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ។ ការតម្រូវធ្វើតេស្តសម្រាប់អ្នកដំណើរដែលចូលមកកម្ពុជាត្រូវបានលុបចោលចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២

## តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩

| | | | | |
|---|---|---|---|---|
| បច្ចុប្បន្នភាព អេពីដេមីសាស្ត្រ អំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
| | ៩៦៣៣ | ២៩៩ | ១ | ២ |
| | ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | ២.៦១០.៩៨៥ | ១៣៦.០៧៦ | ៣.០៥៤ | |
| | ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | ករណីសរុប | ករណីស្លាប់សរុប | |

| | | | |
|---|---|---|---|
| ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩ | 79 | 145 | 1,626 |
| | ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

តារាងទី២. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញ វ័យ និងកុមារ)

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី៦០ឆ្នាំ | អាយុចាប់ពី១៨ឆ្នាំ | អាយុ៣-៥ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំដល់ក្រោម១២ឆ្នាំ | អាយុចាប់១២ឆ្នាំដល់ក្រោម១៨ឆ្នាំ |
| | **(N=43,646)** | **(N=1,378,688)** | **(N=10,000,000)** | **(N=610,730)** | **(N=304,317)** | **(N=1,897,382)** | **(N=1,827,348)** |
| ចាប់ផ្តើម | 10 កុម្ភៈ 2021 | 10 កុម្ភៈ 2021 | 10 កុម្ភៈ2021 | 22 កុម្ភៈ 2022 | 1 វិច្ឆិកា 2021 | 17 កញ្ញា 2021 | 1 សីហា 2021 |
| **ដូសទី១** | 43,646 (100%) | 1,410,594 (102.3%) | 10,274,445 (102.7%) | 322,719 (52.8%) | 379,850 (124.8%) | 2.047,218 (107.8%) | 830,876 (100.2%) |
| **ដូសទី២** | 43,646 (100%) | 1,394,086 (101.1%) | 9,930,003 (99.3%) | 136,495 (22.3%) | 300,481 (98.7%) | 1,977,865 (104.2%) | 1,766,061 (96.6%) |
| **ដូសទី៣** | 43,646 (100%) | 863,989 (62.7%) | 5,907,671 (59.7%) | N/A | 3,216 (1.1%) | 888,033 (46.8%) | 1,230,669 (67.3%) |
| **ដូសទី៤** | 1,232,144 (12.3 %) | | | N/A | N/A | N/A | N/A |

តារាងទី៣. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩

| ប្រភេទវ៉ាក់សាំង កូវីដ-១៩ | **Sinovac** | Sinopharm | AstraZeneca (Covishield) | **Janssen** (Ad26.COV2-S) | **AstraZeneca** (Vaxzevria) | **Moderna** (Spikevax) | **Pfizer** BioNTech (Comirnary) | **សរុប** |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 101 | 79 | 29 | 4 | 1 | 3 | 0 | **217** |
| ចំនួនដូសសរុបបានចាក់ | 24,084,168 | 7,466,841 | 323,344 | 1,053,151 | 2,725,906 | 349,239 | 971,809 | **36,974,458** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.42 | 1.06 | 8.97 | 0.38 | 0.04 | 0.86 | 0 | **0.59** |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។